CIPE | CENTER FOR INTERNATIONAL PRIVATE ENTERPRISE

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

# ឯកសារទស្សនទាន
# ការបណ្តុះបណ្តាលស្តីពី
# "ការពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា តាមរយៈទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល"

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) គឺជាគេហទំព័រ "ទិន្នន័យបើកទូលាយ" ដែលបង្កើតដំបូងគេនៅតំបន់អាស៊ីអាគ្នេយ៍។ ចលនាទិន្នន័យបើកទូលាយ គឺផ្អែកលើការសន្មតដ៏សាមញ្ញមួយថា ទិន្នន័យទាំងឡាយណាដែលត្រូវបានប្រមូលផ្តុំសម្រាប់ប្រយោជន៍សាធារណៈគួរតែដាក់ឱ្យប្រើប្រាស់បានជាសាធារណៈ ដោយគ្មានការដាក់កំហិតឡើយ។ ព័ត៌មាន ឬ ទិន្នន័យទាក់ទងនឹងវិស័យសាធារណៈគួរផ្តល់ឱ្យដោយសេរីដល់គ្រប់ៗគ្នា ដើម្បីប្រើប្រាស់និងផ្សព្វផ្សាយតាមសេចក្តីត្រូវការ។ អូឌីស៊ីមិនលើកស្ទួយឬផ្សព្វផ្សាយទស្សនៈ របៀបវារៈ ឬការលម្អៀងណាមួយ ក្រៅពីផ្តល់ព័ត៌មានជាសត្យានុម័តអំពីប្រទេសកម្ពុជា និងការអភិវឌ្ឍក្នុងប្រទេសឡើយ។

## អំពីគម្រោង

ដោយមានការផ្លាស់ប្តូររចនាសម្ព័ន្ធ សេដ្ឋកិច្ចប្រទេសកម្ពុជាបានបង្ហាញកំណើនយ៉ាងឆាប់រហ័ស ចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៩។ កំណើននេះបានផ្តល់មកនូវការកើនឡើងនៃប្រាក់ចំណូល និងការថយចុះនៃភាពក្រីក្រ ជាមួយនឹងអត្រានៃភាពក្រីក្រថយចុះពី៣៣.៨% ក្នុងឆ្នាំ២០០៩ មក១៧.៨%នៃប្រជាជនសរុបក្នុងឆ្នាំ២០១៩/២០ នេះបើយោងតាមអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា។[1] ជាក់ស្តែង សហគ្រាសធុនមីក្រូ តូច និងមធ្យម ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនប្រាក់ចំណូល បង្កើតឱកាសការងារ កាត់បន្ថយចំណាកស្រុក និងជំរុញទាំងសេដ្ឋកិច្ចជាតិទាំងការអភិវឌ្ឍវិស័យឯកជន។ វិស័យនេះរួមចំណែក៦៣%ទៅក្នុងផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា និងផ្តល់ការងារជាង៧០%នៃកម្លាំងពលកម្មក្នុងវិស័យមិនមែនកសិកម្ម។[2] ដោយឡែក ៨៩.៨%នៃអង្គភាពសេដ្ឋកិច្ចដែលត្រូវបានអង្កេត (៧៥៣,៦៧០អង្គភាព) មិនទាន់ចុះបញ្ជីនៅឡើយទេ[3] ព្រមទាំងប្រឈមនូវបញ្ហាផ្សេងៗដូចជា លទ្ធភាពទទួលហិរញ្ញវត្ថុនិងចូលក្នុងទីផ្សារមានដែនកំណត់ ការយល់ដឹងផ្នែកច្បាប់នៅមានកម្រិត ការទាញយកប្រយោជន៍ពីទិន្នន័យនិងឌីជីថលនៅខ្វះខាត និងការទទួលការគាំទ្រលើការស្តារឡើងវិញអំឡុងពេលវិបត្តិពីរដ្ឋាភិបាលមានកំណត់។

ដូច្នេះ ការលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់ បរិយាបន្នហិរញ្ញវត្ថុ ទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល គឺជាមធ្យោបាយដ៏ចាំបាច់ក្នុងការផ្តល់សិទ្ធិអំណាចដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ព្រមទាំងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ វិធីទាំងនេះអាចជួយពង្រឹងសមត្ថភាពក្នុងការសម្រេចចិត្ត សម្រួលលទ្ធភាពទទួលបានមូលធន ព័ត៌មានទីផ្សារ និងអន្តរាគមន៍ពីរដ្ឋាភិបាល កសាងភាពធន់ និងអាចឱ្យពួកគេចូលរួមយ៉ាងពេញលេញនៅក្នុងសេដ្ឋកិច្ចឌីជីថល។ នៅក្នុងគម្រោង "**ការពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា តាមរយៈទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល**" ដែលទទួលបានជំនួយហិរញ្ញវត្ថុពីមជ្ឈមណ្ឌលសម្រាប់សហគ្រាសឯកជនអន្តរជាតិ អូឌីស៊ីនឹងរៀបចំការបណ្តុះបណ្តាលក្នុងគោលបំណងផ្តល់ឱ្យសហគ្រាស

[1] World Bank, Cambodia poverty assessment, https://openknowledge.worldbank.org/entities/publication/71c8cd7a-b28b-5688-ba89-5c95af5b4994
[2] Phnom Penh Post, Cambodia's first national MSME Day navigating opportunities and challenges, https://www.phnompenhpost.com/business/cambodia-s-first-national-msme-day-navigating-opportunities-and-challenges
[3] National Institute of Statistics, Economic census of Cambodia 2022, https://www.nis.gov.kh/index.php/en/about/general-information/30-ec/115-cambodia-economic-census-2022

ធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា នូវចំណេះដឹង ជំនាញ និងឱកាសកសាងបណ្ដាញទំនាក់ទំនងដែលចាំបាច់សម្រាប់ជំរុញសមិទ្ធកម្មនិងភាពធន់នៃអាជីវកម្ម តាមរយៈការយល់ដឹងផ្នែកច្បាប់ ហិរញ្ញវត្ថុ និងអាជីវកម្ម រួមទាំងការប្រើប្រាស់ទិន្នន័យនិងឌីជីថលដោយការទទួលខុសត្រូវ។

## គោលបំណង

គោលបំណងនៃការបណ្ដុះបណ្ដាលនេះមានដូចតទៅ៖

- លើកកម្ពស់ការយល់ដឹងរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធអំពីទិដ្ឋភាពច្បាប់ដែលគ្របដណ្ដប់លើវិស័យឯកជន និងជម្រើសនៃលទ្ធភាពទទួលបានហិរញ្ញវត្ថុ
- ផ្ដល់មកនូវជំនាញដែលអាចអនុវត្តបាន ក្នុងការទាញយកនិងប្រើប្រាស់ទិន្នន័យបើកទូលាយសម្រាប់ការធ្វើសេចក្ដីសម្រេចដែលមានមូលដ្ឋាន និងផែនការយុទ្ធសាស្ត្រ
- ណែនាំឧបករណ៍ឌីជីថលនិងថ្នាលឌីជីថល ដើម្បីជំរុញសមិទ្ធកម្មនិងទំនាក់ទំនងជាមួយអតិថិជនរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## លទ្ធផលរំពឹងទុក

ក្រោយចប់ការបណ្ដុះបណ្ដាលនេះ អ្នកចូលរួមនឹង៖

- យល់ដឹងកាន់តែប្រសើរពីបទប្បញ្ញត្តិដែលគ្របដណ្ដប់លើវិស័យឯកជន
- ទាញយកនិងប្រើប្រាស់ប្រភពទិន្នន័យបើកទូលាយដែលពាក់ព័ន្ធសម្រាប់ការស្រាវជ្រាវទីផ្សារនិងការធ្វើផែនការអាជីវកម្ម
- ប្រើប្រាស់ឧបករណ៍ឌីជីថលសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុមូលដ្ឋាន ការធ្វើទីផ្សារ និងទំនាក់ទំនងជាមួយអតិថិជន
- យល់ដឹងពីហានិភ័យឌីជីថលនិងការអនុវត្តល្អ ដើម្បីធានាឯកជនភាពទិន្នន័យនិងសន្តិសុខសាយប័រ
- ផ្សារភ្ជាប់ជាមួយម្ចាស់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលចូលរួមជាមួយគ្នានោះ ដើម្បីផ្លាស់ប្ដូរចំណេះដឹងនិងបទពិសោធន៍។

## អ្នកចូលរួមគោលដៅ

ការបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើងសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ជាពិសេសសម្រាប់អ្នកដែលមកពីតំបន់ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ នៅក្នុងគោលដៅដូចជា **រាជធានីភ្នំពេញ ខេត្តសៀមរាប មណ្ឌលគិរី និងកំពត**។ ស្ត្រី និងអ្នកដែលមានបទពិសោធនិងចំណេះដឹងមានកម្រិតលើផ្នែកច្បាប់ ហិរញ្ញវត្ថុ និងអក្ខរកម្មឌីជីថល ត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យចូលរួម។ មានតែអ្នកដែលត្រូវបានជ្រើសរើសប៉ុណ្ណោះ នឹងទទួលបានព័ត៌មានបន្ថែមអំពីកម្មវិធី។

## អំពីប្រព័ន្ធផ្សព្វផ្សាយនិងទំនាក់ទំនង

អូឌីស៊ីបន្តផ្សព្វផ្សាយធនធានដ៏សម្បូរបែបអំពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យមនៅកម្ពុជា ដូចជាកញ្ចប់ព័ត៌មានសហគ្រាសធុនតូចនិងមធ្យម ទំព័រសហគ្រាសធុនតូចនិងមធ្យម ឯកសារច្បាប់ពាក់ព័ន្ធ និងធនធានអប់រំផ្សេងទៀត។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖

ទំព័រហ្វេសប៊ុក៖ Open Development Cambodia

គេហទំព័រ៖ https://opendevelopmentcambodia.net/